# Filartiga Case[1]

**១.** សហរដ្ឋអាមេរិក មានច្បាប់មួយគឺ Alien Tort Act អនុម័តក្នុងឆ្នាំ១៧៨៩ ផ្តល់យុត្តាធិការដល់តុលាការសហព័ន្ធ ពិចារណា នូវបណ្តឹងរដ្ឋប្បវេណី ដោយជនបរទេសរងនូវអំពើបំពានច្បាប់ និងសន្ធិសញ្ញាសហរដ្ឋអាមេរិក ដោយមន្ត្រីបរទេស នៅក្រៅប្រទេសសហរដ្ឋអាមេរិក។[2]

**២.** ច្បាប់នេះ ត្រូវបានសំអាង ដោយកូនរបស់លោក Filartiga ឈ្មោះ Dolly ដែលឪពុកខ្លួនជាអ្នកនយោបាយ ត្រូវបានធ្វើទារុណកម្មដោយលោក Pena ជាមេប៉ូលីសនៃប្រទេស ប៉ារាហ្គាយ។ កូនៗបានប្តឹងនៅក្នុងប្រទេសនេះ ក៏ប៉ុន្តែត្រូវបានគម្រាម ហើយមេធាវីការពារ ត្រូវបានបណ្តេញចេញពីគណៈមេធាវី។ ពួកគេបានប្តឹងនៅតុលាការអាមេរិក ខណៈលឺថា Pena ស្ថិតនៅក្នុងសហរដ្ឋរងចាំការបណ្តេញចេញដោយសារ ការស្នាក់នៅបានផុតរលត់។

៣. តុលាការសហព័ន្ធ Appeals for the Second Circuit បានអះអាងថា៖ *អំពើទារុណកម្មប្រព្រឹត្តដោយមន្ត្រីរដ្ឋប្រឆាំងអ្នកជាប់ឃុំ បំពាននូវវិធានច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដូចនេះប្រឆាំងនឹងច្បាប់មនុស្សជាតិ*។ គំហើញនេះនាំឲ្យមានការផ្លាស់ប្តូរទស្សនៈ ដែលថា ការបំពានសិទ្ធិដោយអាជ្ញាធរលើប្រជាពលរដ្ឋរបស់ខ្លួនឯងគឺជារឿងក្នុងស្រុក ដែលរដ្ឋដទៃមិនត្រូវលូកដៃទេ។ តុលាករនេះ បានតម្លើងកម្រិតវិធាន ហាមឃាត់ទារុណកម្ម ស្មើនឹង ការហាមឃាត់ចោរសមុទ្រ (piracy) ឬការហាមឃាត់ទាសភាព (slavery) ដែលជាសត្រូវនៃគ្រប់ប្រជាជាតិ (*hostis humani generis*)។

**៤.**ទោះបីជាយ៉ាងនេះក្តី យុត្តិសាស្ត្រនេះត្រូវបានរិះគន់ថា អាចបំពានទ្រឹស្តីបែងចែកអំណាច ដោយសារការផ្តល់សិទ្ធិក្នុងការប្តឹងផ្តល់។ អាស្រ័យហេតុនេះ ទើបតុលាការកំពូលសហរដ្ឋអាមេរិក ក្នុង *Sosa v. Alvarez-Machain,* 542 U.S. 692 បានបកស្រាយការបំពានសិទ្ធិដែលជា (អំពើអនីត្យានុកូលភាព) ជាកម្មវត្ថុប្តឹងក្រោម ច្បាប់ Alien Tort Act ចង្អៀតដើម្បីកុំឲ្យប៉ះការងារការទូតរបស់នីតិប្រតិបត្តិ។

**៥.**វាមានបញ្ហាក្នុងការអនុវត្តច្បាប់នេះ ដោយសារ ចុងចម្លើយ បានចាកចេញពីសហរដ្ឋអាមេរិក មុនសវនាការ និងមិនមានទ្រព្យច្រើន ក្នុងសហរដ្ឋអាមេរិក ដែលអាចត្រូវបានរឹបអូសដើម្បីសងសំណង។

---

[1] *Filartiga v. Pena-Irala*, US Court of Appeals for the Second Circuit, 30 June 1980, 630 F.2nd 876 (2nd Cir.1980).

[2] Any civil action by an alien for a tort only, committed in violation of the law of nations or a treaty of the United States,

**<u>ដកស្រង់ពី Filartiga ដោយ Jens Ohlin ក្នុង Antonio Cassese, The Oxford Companion to International Criminal Justice, 2009, pp. 671-673.</u>**

**<u>កំណត់សំគាល់</u>៖**

**ក.** អំពើទារុណកម្ម ត្រូវមានហាមឃាត់ក្នុងមាត្រា ៧ នៃកតិកាសញ្ញាឆ្នាំ ១៩៧៧ ស្តីពីសិទ្ធិប្រជាពលរដ្ឋ និងនយោបាយ៖ *គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬការប្រព្រឹត្តិ ឬទណ្ឌកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬធ្វើឲ្យថោកទាបឡើយ។ ជាពិសេស ហាមយកជនណាម្នាក់មកធ្វើការពិសោធខាងវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រ ដោយគ្មានការយល់ព្រមដោយសេរីពីសាម៉ីខ្លួនឡើយ។* ។ក្រមព្រហ្មទណ្ឌកម្ពុជា បានចាត់អំពើទារុណកម្ម ជា បទល្មើសព្រហ្មទណ្ឌក្នុងមាត្រាមាត្រា ២១០៖ *ទារុណកម្ម ឬអំពើឃោរឃៅដែលប្រព្រឹត្តទៅលើបុគ្គលណាមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំទៅ ១៥ (ដប់ប្រាំ) ឆ្នាំ* ។

**ខ.** សូមមើល ពាក្យគន្លឹះពាក់ព័ន្ធដូចជា *Jus cogens*, យុត្តាធិការសកល (universal jurisdiction) ការអនុវត្តច្បាប់សិទ្ធិមនុស្សក្រៅដែនដី (extraterritorial application of human rights norms)។ សម្រាប់អត្ថបទស្តីពីការហាមឃាត់អំពើទារុណកម្ម សូមមើល http://www.measboralaws.com/detail/12.